**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ០៧១៣៧ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## រំលឹកអំពីការប្រើប្រាស់វិក្កយបត្រ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជំរាបជូនដំណឹងដល់ លោកឧកញ៉ា លោក លោកស្រី ជាម្ចាស់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់មេត្តាជ្រាបថា យោងតាមបទប្បញ្ញត្តិនៃមាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធទាំងអស់ត្រូវចេញវិក្កយបត្រលើរាល់ការផ្គត់ផ្គង់ទំនិញឬសេវា និងត្រូវកាន់កត់ត្រាបញ្ជិកាគណនេយ្យឲ្យបានត្រឹមត្រូវ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថាសហគ្រាសមួយចំនួនបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិដូចបានជម្រាបជូនខាងលើ ប៉ុន្តែសហគ្រាសមួយចំនួនទៀតមិនបានអនុវត្តត្រឹមត្រូវ ដោយមិនបានចេញវិក្កយបត្រ ឬចេញវិក្កយបត្រដែរតែវិក្កយបត្រទាំងនោះគ្មាននិទ្ទេសត្រឹមត្រូវដែលអាចទទួលយកបានឡើយ។

ក្នុងគោលដៅពង្រឹងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ និងដើម្បីធានានូវតម្លាភាពក្នុងការគ្រប់គ្រងចំណូលសារពើពន្ធ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដល់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់អំពីវិធាននៃការប្រើប្រាស់វិក្កយបត្រដូចខាងក្រោម ៖

១- ត្រូវចេញវិក្កយបត្រលើរាល់ការផ្គត់ផ្គង់ទំនិញឬសេវា ដែលក្នុងនោះត្រូវចេញវិក្កយបត្រអាករ(Tax invoice)ឲ្យអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា និងចេញវិក្កយបត្រធម្មតា(Commercial Invoice)ឲ្យអ្នកជាប់ពន្ធតាមរបបម៉ៅការ ឬអតិថិជននានាដែលជាអ្នកប្រើប្រាស់ចុងក្រោយ។

២- វិក្កយបត្រត្រូវមាននិទ្ទេសសំខាន់ៗមួយចំនួនជាចាំបាច់ដូចជា៖
- ក- ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្ម អតប (VATTIN) របស់សហគ្រាសជាអ្នកលក់
- ខ- កាលបរិច្ឆេទចេញវិក្កយបត្រ
- គ- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងលេខអត្តសញ្ញាណកម្មអតប ប្រសិនបើអ្នកទិញជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- ឃ- បរិមាណ សេចក្តីបរិយាយនិងថ្លៃលក់ទំនិញឬសេវា
- ង- តម្លៃសរុបដែលមិនទាន់គិតអាករនិងប្រាក់អាករដាច់ដោយឡែកក្នុងករណីចេញវិក្កយបត្រអាករ ឬតម្លៃសរុបរួមបញ្ចូលទាំងអាករ ក្នុងករណីចេញវិក្កយបត្រធម្មតា (គម្រូវិក្កយបត្រមាននៅខាងខ្នងនៃលិខិតនេះ)។

៣- អ្នកជាប់ពន្ធត្រូវប្រើប្រាស់វិក្កយបត្រតាមលំដាប់លេខរៀងឲ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកក្នុងរយៈពេល ១០ឆ្នាំ ។

យោងតាមមាត្រា១២៨នៃច្បាប់ស្តីពីសារពើពន្ធ ការកាន់កត់ត្រាបញ្ជិកាគណនេយ្យមិនត្រឹមត្រូវ ការមិនចេញវិក្កយបត្រ ឬចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវបានចាត់ទុកថាជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រូវរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា៧៨ មាត្រា១៣៣ និងមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមានការបិទគ្រឹះស្ថានអាជីវកម្មក្នុងរយៈពេលមួយមានកំណត់ ការកំណត់ពន្ធបន្ថែមឬការប្តឹងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់រហូតដល់១០.០០០.០០០រៀល ឬជាប់ពន្ធនាគាររហូតដល់១ឆ្នាំ ឬទោសទាំងពីរ។

អគ្គនាយកដ្ឋានពន្ធដារនឹងចាត់មន្ត្រីឲ្យចុះដល់ទីកន្លែងប្រកបអាជីវកម្មរបស់សហគ្រាស ដើម្បីត្រួតពិនិត្យការប្រើប្រាស់វិក្កយបត្រដូចបានជម្រាបជូនខាងលើ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថា លោកឧកញ៉ា លោក លោកស្រី ជាម្ចាស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

# គម្រូវិក្កយបត្រអាករ

## វិក្កយបត្រអាករ

TAX INVOICE

លេខរៀងវិក្កយបត្រ ៖ 000001

ចុះថ្ងៃទី....... ខែ........ ឆ្នាំ..........

**ក្រុមហ៊ុន** ..............................................

អាសយដ្ឋាន៖ លេខ............ ផ្លូវ.........................

សង្កាត់....................ខណ្ឌ.....................ភ្នំពេញ

លេខអត្តសញ្ញាណកម្មអតប...............................

**លក់ជូន ៖**

.................................................................

អាសយដ្ឋាន៖ លេខ..........ផ្លូវ.................សង្កាត់..............ស្រុក/ខណ្ឌ................ខេត្ត/ក្រុង............... លេខអត្តសញ្ញាណកម្មអតប...............................

| លរ. | បរិយាយមុខទំនិញ | បរិមាណ | ថ្លៃឯកតា | ថ្លៃទំនិញ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | បូកសរុប | |
| | | | អាករលើតម្លៃបន្ថែម១០% | |
| | | | សរុបរួម | |

ហត្ថលេខានិងឈ្មោះអ្នកទិញ

ហត្ថលេខានិងឈ្មោះអ្នកលក់

*សម្គាល់ ៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់*

# គម្រូវិក្កយបត្រធម្មតា

## វិក្កយបត្រ

INVOICE

លេខរៀងវិក្កយបត្រ ៖ 000001

ចុះថ្ងៃទី....... ខែ........ ឆ្នាំ..........

**ក្រុមហ៊ុន** ..............................................

អាសយដ្ឋាន៖ លេខ............ ផ្លូវ.........................

សង្កាត់....................ខណ្ឌ.....................ភ្នំពេញ

លេខអត្តសញ្ញាណកម្មអតប...............................

**លក់ជូន ៖**

.................................................................

អាសយដ្ឋាន៖ លេខ..........ផ្លូវ...................សង្កាត់.....................ស្រុក/ខណ្ឌ..................ខេត្ត/ក្រុង ............................

| លរ. | បរិយាយមុខទំនិញ | បរិមាណ | ថ្លៃឯកតា | ថ្លៃទំនិញរួមទាំងអាករ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| សរុបរួមថ្លៃទំនិញរួមទាំងអាករ | | | | |

ហត្ថលេខានិងឈ្មោះអ្នកទិញ

ហត្ថលេខានិងឈ្មោះអ្នកលក់

*សម្គាល់ ៖ ច្បាប់ដើមសម្រាប់អ្នកទិញ ច្បាប់ចម្លងសម្រាប់អ្នកលក់*